**សិក្ខាសាលាស្តីពីការណែនាំលើការអនុវត្តការបញ្រ្ជាបយេនឌ័រ**
**២០១១និងរៀបចំផែនការសកម្មភាពនិងថវិកាឆ្នាំ៣ក្នុងផអ**
ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១១
ទីស្តីការក្រសួងកិច្ចការនារី (កុលាប១)

---

សន្ទរកថាបើករបស់ឯកឧត្តម **ខាន់ ចំរើន**
អគ្គនាយករងអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ និង
ជាអនុប្រធានអចិន្ត្រៃយ៍លេខាធិការដ្ឋាន គ.ជ.អ.ប

- លោកជំទាវ **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី
- លោកជំទាវរដ្ឋលេខាធិការ លោកជំទាវ ឯកឧត្តមថ្នាក់ដឹកនាំក្រសួងកិច្ចការនារី
- លោកស្រីប្រធាន និង លោក លោកស្រី មន្ត្រីមន្ទីរកិច្ចការនារីរាជធានី ខេត្ត
- លោក លោកស្រីតំណាងដៃគូរអភិវឌ្ឍន៍
- លោក លោកស្រីមន្ត្រី និងទីប្រឹក្សាលេខាធិការដ្ឋាន គ.ជ.អ.ប ជាទីគោរព

ជំនួសមុខអោយឯកឧត្តមប្រធានលេខាធិការដ្ឋានគ.ជ.អ.ប ថ្ងៃនេះខ្ញុំមានកិត្តិយសនិងសេចក្តីសោមនស្សរីករាយជាខ្លាំងដែលបានចូលរួមក្នុងពិធីបើកសិក្ខាសាលា ស្តីពីការណែនាំលើការអនុវត្តការបញ្ជ្រាបយេនឌ័រក្នុងផអ៣ និង ការរៀបចំផែនការសកម្មភាពនិងថវិកាឆ្នាំ ២០១១សម្រាប់ក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារីរាជធានី ខេត្ត។

លោកជំទាវ អស់លោក លោកស្រី ប្រហែលជាបានជ្រាបហើយថា យើងមានសិក្ខាសាលា ស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១១សម្រាប់ថ្នាក់ក្រោមជាតិ កាលពីដើមខែមិថុនា ឆ្នាំ២០១១ ។ ដោយឡែកក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី នឹងត្រូវរៀបចំផែនការសកម្មភាព និងថវិកាក្នុងសិក្ខាសាលារយៈពេល០២ថ្ងៃនេះ ។ ភាពយឺតយ៉ាវនៃការរៀបចំនេះ គឺដោយសារយើងចំណាយពេលវេលាច្រើនក្នុងការពិភាក្សានិងឯកភាពលើ<u>របៀបអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ផអ៣</u> ។

មកដល់ត្រង់ចំណុចនេះខ្ញុំសូមយកឱកាសជម្រាបជូន លោកជំទាវ អស់លោក លោកស្រីអោយបានជ្រាបថារាជរដ្ឋាភិបាលបានទទួលស្គាល់ថាតួនាទីបុរស និងស្ត្រី ឬយេនឌ័រគឺជាបញ្ហាអន្តរវិស័យ ហើយបាន

នានាក្នុងនាមជាសមាជិករបស់ គ.ជ.អ.ប ក្នុងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ក្របខណ្ឌច្បាប់ និងសេចក្តីណែនាំនានាទាក់ទងនឹងយេនឌ័រ។ ដើម្បីឈានទៅមុខកាន់តែប្រសើរថែមទៀត យើងចាំបាច់ត្រូវពង្រឹងបន្ថែមនូវជោគជ័យទាំងនេះ និងដោះស្រាយនូវបញ្ហារាំងស្ទះនានាអោយបានដើម្បីឈានទៅសម្រេចនូវសមភាពយេនឌ័រយ៉ាងពិតប្រាកដនៃកំណែទម្រង់របស់យើង ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមឯកឧត្តមប្រធានលេខាធិការដ្ឋាន ខ្ញុំសូមបញ្ជាក់សារឡើងវិញថា សមភាពយេនឌ័រ គឺជាបញ្ហាអាទិភាព និងអន្តរវិស័យក្នុងដំណើរការកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។

ខ្ញុំសង្ឃឹមថា តាមរយៈសិក្ខាសាលារយៈពេល០២ថ្ងៃនេះ ក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារីទាំង២៤រាជធានី ខេត្តនឹងបានបញ្ចប់ចុងក្រោយនូវផែនការសកម្មភាព និងថវិកាឆ្នាំ២០១១ ដោយពិចារណាទៅលើធនធានដែលមាន សមត្ថភាពនាពេលបច្ចុប្បន្ន និង ពេលវេលាដែលនៅសេសសល់ក្នុងឆ្នាំនេះ ក៏ដូចជាត្រៀមលក្ខណៈពិភាក្សា និងពិចារណាផងដែរចំពោះសកម្មភាពណាដែលត្រូវអនុវត្តនៅឆ្នាំក្រោយ ។

ជាទីបញ្ចប់ខ្ញុំសូមជូនពរលោកជំទាវរដ្ឋមន្ត្រី លោកជំទាវ ឯកឧត្តមថ្នាក់ដឹកនាំក្រសួងកិច្ចការនារី លោកស្រីប្រធានមន្ទីរកិច្ចការនារី និងលោកស្រី អស់លោក ដែលជាសិក្ខាកាមទាំងអស់ទទួលបាននូវសុខភាពល្អ និងជ័យជំនះគ្រប់ភារកិច្ច ។

សូមអរគុណ ។